**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# **សាលក្រមព្រហ្មទណ្ឌ**

- លេខ ៦៨ “ម” ក្រ.៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤
- សំណុំរឿងព្រហ្មទណ្ឌលេខ ២០៥២ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣
- សំណុំរឿងស៊ើបសួរលេខ ១៥៧១ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣
- សំណុំរឿងជំនុំជម្រះលេខ ៤៥៥៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣

## **តាងនាមប្រជារាស្ត្រខ្មែរ**
## **សាលាដំបូងរាជធានីភ្នំពេញ**

បើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ នៅសាលសវនាការទី១ ដោយមានសមាសភាព៖

### **ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក[redacted] ជាចៅក្រមប្រឹក្សា

### **តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### **ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០៥២ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា ហៅ អាយ៉ា** ភេទប្រុស អាយុ១៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]សុឈឿន “រស់” ម្ដាយឈ្មោះ [redacted]បុប្ផា “រស់” នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ក្រៅឃុំ)។

- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៥៩៣៦ “ង” ង.ឃ.ង ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៣។

ត្រូវបានចោទប្រកាន់ពីបទ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

- លោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] មានការិយាល័យនៅក្រុមមេធាវី ដឹហ្វេក (The Flag)ផ្ទះលេខ២អ។ ផ្លូវលេខ៥៦៦ កែងផ្លូវ៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា។



Scanned with CamScanner

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុភ័ក ភេទស្រី អាយុ៣០ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅបន្ទប់ជួលលេខ១៨ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាម្តាយជនរងគ្រោះឈ្មោះ [redacted] លីណា។
- មេធាវី [redacted] ជាមេធាវីប្រចាំអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានការិយាល័យផ្ទះលេខ៤២ អេហ្វ ផ្លូវលេខ៨៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក។

## អង្គហេតុដែលត្រូវបានចោទប្រកាន់

កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ នៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានករណី រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ដែលបង្កឡើងដោយឈ្មោះ [redacted]ពុធធារ៉ា ហៅ អាយ៉ា បាននាំជនរងគ្រោះឈ្មោះ[redacted] លីណា ភេទស្រី អាយុ១៤ ឆ្នាំ ទៅលេងផ្ទះ ហើយជនជាប់ចោទក៏បាននាំជនរងគ្រោះរួមភេទជាមួយគ្នាបានសម្រេចចំនួន០១ ដង ដោយមិនពាក់ស្រោម។ លុះរំលងបាន១ ខែ ជនរងគ្រោះនិងជនជាប់ចោទបានរួមភេទជាមួយគ្នាម្តងទៀតដោយមិនពាក់ស្រោមដដែល។ នៅពេលដឹងខ្លួនថាមានផ្ទៃពោះ ជនរងគ្រោះក៏បានឱ្យជនជាប់ចោទមកទទួលខុសត្រូវ ប៉ុន្តែជនជាប់ចោទមិនព្រម។ លុះដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ម្តាយរបស់ជនរងគ្រោះឈ្មោះ [redacted]សុភ័ក អាយុ៣០ ឆ្នាំ ឃើញក្បាលពោះកូនខុសធម្មតាក៏សួរនាំ ហើយជនរងគ្រោះក៏បានរៀបរាប់អំពីដំណើររឿងដែលខ្លួនបានប្រព្រឹត្ត ហើយម្តាយជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ តែម្តង។

- បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted]សុភ័ក។
- បានឃើញ របាយការណ៍សរុបលេខ ១២ រ.ប.ក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។
- បានឃើញ ពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សុភ័ក។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥៥២ អ.យ.ង ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៣០៣ អ.យ.ង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨៤៤ ស.ដ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## ដំណើរការ នៃកិច្ចពិភាក្សាដេញដោល

១. អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា ខ្ញុំបាទទទួលស្គាល់ ថាពិតជាបានរួមភេទជាមួយឈ្មោះ [redacted] លីណា បានចំនួន២ លើកពិតប្រាកដមែន។ លើកទី១ នៅអំឡុងខែមិថុនា ឆ្នាំ២០២២ និងលើកទី២ នៅអំឡុងខែសីហា ឆ្នាំ២០២២។ ការរួមភេទទាំងពីរលើកនេះកើតមកពីការព្រមព្រៀងដោយមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។ ខ្ញុំមិនបានដឹងថាឈ្មោះ [redacted] លីណា មានអាយុទើបតែ១៤ ឆ្នាំនោះទេ ព្រោះនៅពេលទំនាក់ទំនងគ្នា ខ្ញុំក៏ធ្លាប់សួរបញ្ជាក់អាយុរបស់គាត់ដែរ ហើយគាត់បានបញ្ជាក់ថាគាត់



Scanned with CamScanner

(វ៉ិច លីណា) មានអាយុ១៦ ឆ្នាំ ហើយពួកយើងក៏ទំនាក់ទំនងគ្នារហូតឈានដល់ការរួមភេទតែម្តង។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបានដកហូតទូរស័ព្ទម៉ាក IPhone ពណ៌ផ្កាឈូកមួយគ្រឿង ក្រៅពីនេះពុំមានអ្វីផ្សេងៗទៀតឡើយ។ ខ្ញុំបាទសុំតុលាការកុំឃុំខ្លួនខ្ញុំអី ព្រោះនៅក្នុងរឿងនេះខ្ញុំបាទមិនបានដឹងជាមុនថា ជនរងគ្រោះមានអាយុតិចជាង១៥ឆ្នាំនោះទេ ដោយសារពេលទាក់ទងគ្នារឿងស្នេហា ជនរងគ្រោះបានបញ្ជាក់ថា គាត់មានអាយុ១៦ឆ្នាំ ហើយម្យ៉ាងទៀតសព្វថ្ងៃខ្ញុំជាកូនសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ និងត្រូវប្រលងមធ្យមសិក្សាទុតិយភូមិនៅចុងឆ្នាំនេះ លើសពីនេះទៅទៀតខ្ញុំជាជនពិការ (ពិការភ្នែកខាងស្តាំ) ដែលត្រូវមានការពិនិត្យមើលថែជាប្រចាំ។

២. អំណានចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក បានឆ្លើយបំភ្លឺថា ឈ្មោះ [redacted] លីណា ដែលជាកូនស្រីរបស់ខ្ញុំសព្វថ្ងៃនាងរៀនថ្នាក់ទី៨។ ការរស់នៅជាមួយគ្នាសព្វថ្ងៃខ្ញុំពុំដែលដឹងថាកូនស្រីមានទំនាក់ទំនងស្នេហាជាមួយបុរសណាទេ។ ជាក់ស្តែងនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១០ព្រឹក ខ្ញុំបានជជីកសួរនាំកូនស្រី ហើយនាងបានប្រាប់ខ្ញុំថា នាងមានទំនាក់ទំនងស្នេហាជាមួយសង្សាម្នាក់ឈ្មោះ [redacted] ពុធធារ៉ា ហើយព្រមទាំងមានកូនក្នុងផ្ទៃពោះចំនួន៨ ខែ ពេលលឺកូនប្រាប់ដំណើររឿងរបស់នាងរួច ខ្ញុំក៏មានអារម្មណ៍តក់ស្លុតក៏នាំកូនស្រីខ្ញុំមកដាក់ពាក្យបណ្តឹងនៅកន្លែងសមត្ថកិច្ចតែម្តង។

ខ្ញុំសូមបញ្ជាក់ថា ចាប់តាំងពីកូនរបស់ខ្ញុំមានសង្សារហូតដល់មានផ្ទៃពោះចំនួន៨ ខែ គឺខ្ញុំពុំដែលដឹងទាល់តែសោះ ខ្ញុំជជីកសួររហូតដល់នាងប្រាប់ថានាងមានផ្ទៃពោះ ទើបខ្ញុំនាំកូនស្រីទៅពិនិត្យផ្ទៃពោះនៅមន្ទីរពេទ្យឯកជនមួយកន្លែងឈ្មោះ កន្និដ្ឋា លទ្ធផលឃើញថានាងមានផ្ទៃពោះចំនួន ៣២ សប្តាហ៍។ បន្ទាប់មកខ្ញុំក៏បានទាក់ទងទៅវិទ្យុABC ដើម្បីសុំយោបល់ ហើយខាងវិទ្យុក៏បានផ្តល់ព័ត៌មានឱ្យទៅមន្ទីរកិច្ចការនារី ខាងក្រសួងកិច្ចការនារី បានណែនាំឱ្យខ្ញុំយកកូនស្រីឈ្មោះ [redacted] លីណា មកដាក់ពាក្យបណ្តឹងនៅកងរាជអាវុធហត្ថរាជធានីភ្នំពេញ។ ក្រោយពីបានឃាត់ខ្លួនឈ្មោះ ផាន់ ពុធធារ៉ា ខាងក្រុមគ្រួសាររបស់គេបានមកសម្របសម្រួលជាមួយខ្ញុំដោយសារឈ្មោះ [redacted] ពុធធារ៉ា នៅរៀនថ្នាក់ទី១២ ចំណែកកូនខ្ញុំក៏នៅរៀនដែរ ហើយខ្ញុំក៏យល់ព្រមយកសំណងជំងឺចិត្តចំនួន ២.៣០០ (ពីរពាន់បីរយ) ដុល្លារអាមេរិក។ បន្ទាប់មកខ្ញុំក៏បានដាក់ពាក្យសុំដកពាក្យបណ្តឹងប្តឹងលើឈ្មោះ [redacted] ពុធធារ៉ា ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ដោយមានកិច្ចព្រមព្រៀងដំណោះស្រាយបញ្ចប់វិវាទ។

៣. តាមអំណានចម្លើយបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] លីណា បានឆ្លើយបំភ្លឺថា កាលពីអំឡុងឆ្នាំ២០២២ ចុងខែ០៦ ខ្ញុំបានស្គាល់បុរសម្នាក់ឈ្មោះ [redacted] ពុធធារ៉ា រៀននៅវិទ្យាល័យឫស្សីកែវ ថ្នាក់ទី១២ ស្នាក់នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយស្គាល់គ្នាតាមហ្វេសប៊ុកដែលមានឈ្មោះ CRA ស្គាល់គ្នាបានរយៈពេលមួយសប្តាហ៍ ជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា បានណាត់ជួបគ្នា និងបានដើរលេងញ៉ាំអីជាមួយគ្នា រួចជនជាប់ចោទក៏បានដឹកខ្ញុំទៅផ្ទះគាត់ ដោយជិះម៉ូតូម៉ាកស្កុបពី ពណ៌ខ្មៅ មិនចាំផ្លាកលេខ។ លុះប្រហែលវេលាម៉ោង០២ និង០០ នាទី រសៀលពួកខ្ញុំក៏ទៅដល់ទីនោះ ដោយឪពុកម្តាយរបស់ជនជាប់ចោទពួកគាត់នៅលើផ្ទះ មិនដឹងថាពួកខ្ញុំនៅខាងក្រោមផ្ទះទេ។ ភ្លាមនោះជនជាប់ចោទក៏បាននាំខ្ញុំចូលទៅបន្ទប់គាត់ ហើយសុំខ្ញុំរួមភេទជាមួយគ្នាខ្ញុំក៏យល់ព្រម ហើយក៏បានរួមភេទជាមួយគ្នាចំនួន០៣ ដង ដោយលើកទី១ គាត់ដាក់ទឹកចេញក្រៅ ហើយពេលខ្ញុំទៅបន្ទប់ទឹកឃើញមានឈាមនៅប្រដាប់ភេទខ្លួន ចំណែក០២ ដង ចុងក្រោយគឺ ដាក់ទឹកចូល ក្រោយពីរួមភេទរួចខ្ញុំក៏បានចេញពីផ្ទះជនជាប់ចោទដោយជិះម៉ូតូកង់បីមកដោយខ្លួនឯង។ ក្រោយមករយៈពេលមួយខែខ្ញុំសុំជនជាប់ចោទបែកគ្នាមូលហេតុមិនច្បាស់លាស់ជាមួយខ្ញុំដោយមានសង្សាផ្សេងទៀត។ ក្រោយបែកគ្នារយៈពេលមួយខែ ខ្ញុំ និងជនជាប់ចោទក៏បានជួបគ្នាដោយជនជាប់ចោទ



Scanned with CamScanner

ប្រាប់ខ្ញុំថា ប៉ាម៉ាក់គាត់ចង់ជួបខ្ញុំ ហើយជនជាប់ចោទក៏មកឌុបខ្ញុំដោយជិះម៉ូតូដែលយកខ្ញុំទៅមុខបុរីពិភពថ្មីទួលសង្កែ ហើយពេលខ្ញុំទៅផ្ទះគាត់ ខ្ញុំមិនបានឃើញម៉ាក់ប៉ាគាត់ទេ ហើយជនជាប់ចោទប្រាប់ថា ប៉ាម៉ាក់នៅក្រោម ពេលនោះ ជនជាប់ចោទបានទាញដៃខ្ញុំចូលបន្ទប់ ហើយក៏បានសុំខ្ញុំរួមភេទ តែខ្ញុំមិនព្រមទេ តែជនជាប់ចោទនៅតែបង្ខំលួងលោម រហូតដល់ខ្ញុំយល់ព្រមរួមភេទ ដោយមិនប្រើស្រោមអនាម័យបាន១ដង ដោយដាក់ទឹកចូលហើយពេលរួមភេទរួច ជនជាប់ចោទបានដឹកខ្ញុំមកសាលាវិញ។ ក្រោយមកប្រហែលខែ០៩ ឆ្នាំ២០២២ ខ្ញុំដឹងថាខ្ញុំមានកូនដោយវាបំរ៉ាស់ក្នុងពោះ ពេលនឹងខ្ញុំក៏បានឆាតទៅជនជាប់ចោទហើយប្រាប់ថា ខ្ញុំមានកូនហើយ ប៉ុន្តែ ជនជាប់ចោទមិនជឿទេ ខ្ញុំក៏ប្រាប់ថាឱ្យលុយខ្ញុំ ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក មកខ្ញុំយកកូនចេញ ជនជាប់ចោទប្រាប់ថា បើចង់បានលុយមកផ្ទះគាត់មក លើដូចនេះខ្ញុំក៏ទៅផ្ទះជនជាប់ចោទ ពេលទៅដល់ទីនោះជនជាប់ចោទក៏ហៅខ្ញុំចូលទៅបន្ទប់ ហើយក៏បានចាប់បង្ខំខ្ញុំរួមភេទបានសម្រេចម្តងទៀត ដោយដាក់ទឹកចូលពេលរួមភេទ រួចខ្ញុំត្រឡប់មកសាលាវិញធម្មតា។ បន្ទាប់មកជនជាប់ចោទនិងខ្ញុំក៏បានឈប់ទាក់ទងគ្នារហូតដល់សព្វថ្ងៃនេះ ហើយជនជាប់ចោទមិនទទួលខុសត្រូវទេ ទើបខ្ញុំប្តឹងសមត្ថកិច្ចដើម្បីរកយុត្តិធម៌ដល់រូបខ្ញុំ ក្រោយពីបានឃាត់ខ្លួនជនជាប់ចោទមករយៈពេល១ខែជាង ខ្ញុំបានឆ្លងទន្លេបានកូនស្រីម្នាក់។

៤. អំណានរបាយការណ៍សរុបលេខ ១២ រ.ប.ក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានថា ករណីជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា ភេទប្រុស អាយុ១៩ ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ ឆ្នាំ ពិតប្រាកដមែន។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ និងក្រោយពីបានស្តាប់អំណានចម្លើយសារភាពរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា** បានឆ្លើយសារភាពថា ខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] លីណា បានចំនួន ២ លើក ពិតប្រាកដមែន ដោយលើកទី១ នៅអំឡុងខែមិថុនា ឆ្នាំ២០២២ និងលើកទី២ នៅអំឡុងខែសីហា ឆ្នាំ២០២២ ដែលចម្លើយសារភាពនេះ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងចម្លើយបំភ្លឺរបស់ជនរងគ្រោះ។ ដូច្នេះ តំណាងអយ្យការ សូមរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា** តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៣០៣ អ.យ.ង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា ហៅ អាយ៉ា** ពីបទ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៦. លោកស្រីមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា ហៅ អាយ៉ា** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថា ក្នុងសំណុំរឿងនេះត្រូវបានម្តាយជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការដកពាក្យបណ្តឹង ដូចមានក្នុងពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សុភ័ក ដោយដើមបណ្តឹងរដ្ឋប្បវេណីក៏បានទទួលសំណងពីកូនក្តី យើងខ្ញុំរួចរាល់ហើយដែរ ដូច្នេះ យើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីយើងខ្ញុំផង។



Scanned with CamScanner

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. តាមរបាយការណ៍សរុបលេខ ១២ រ.ប.ក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានថា ករណីជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា ភេទប្រុស អាយុ១៩ ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ ឆ្នាំ ពិតប្រាកដមែន។

២. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា** បានឆ្លើយសារភាពថា ខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted]ប៊ីណា បានចំនួន២ លើក ពិតប្រាកដមែន ដោយលើកទី១ នៅអំឡុងខែមិថុនា ឆ្នាំ២០២២ និងលើកទី២ នៅអំឡុងខែសីហា ឆ្នាំ២០២២។ ចម្លើយសារភាពនេះ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងចម្លើយបំភ្លឺរបស់ជនរងគ្រោះ។ ដូច្នេះ តំណាងអយ្យការសូមរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា** តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៣០៣ អ.យ.ង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា ហៅ អាយ៉ា** ពីបទ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ចំពោះការប្តឹងសុំនេះ តុលាការធ្វើការពិនិត្យ និងសម្រេចតាមអង្គហេតុ និងអង្គច្បាប់។

៣. លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ពុធធារ៉ា ហៅ អាយ៉ា** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថា ក្នុងសំណុំរឿងនេះត្រូវបានម្តាយជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការដកពាក្យបណ្តឹង ដូចមានក្នុងពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សុភ័គ ដោយដើមបណ្តឹងរដ្ឋប្បវេណីក៏បានទទួលសំណងពីកូនក្តី យើងខ្ញុំរួចរាល់ហើយដែរ ដូច្នេះ យើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីយើងខ្ញុំផង។ ចំពោះសេចក្តីសន្និដ្ឋានការពារនេះ តុលាការធ្វើការពិនិត្យ និងសម្រេចតាមអង្គហេតុ និងអង្គច្បាប់។

៤. ក្រោយពីបានស្តាប់អំណានរបាយការណ៍សរុបលេខ ១២ រ.ប.ក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងក្រោយពី



Scanned with CamScanner

បានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទថា ខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] លីណា បានចំនួន២ លើក ពិតប្រាកដមែន ដោយលើកទី១ នៅអំឡុងខែមិថុនា ឆ្នាំ២០២២ និងលើកទី២ នៅអំឡុងខែសីហា ឆ្នាំ២០២២ ដូចការលើកឡើងរបស់ជនរងគ្រោះ ដ៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ ឃើញថា ចម្លើយសារភាព នេះគឺមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង ហើយដែលអាចឱ្យតុលាការកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា ពិតជាបានប្រព្រឹត្តនូវអំពើ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចការចោទប្រកាន់ ពិតប្រាកដមែន។

៥. ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ហើយដែលមានចេតនាប្រព្រឹត្តនូវអំពើរបស់ខ្លួន ដែលបានធ្វើឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។

៦. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានទាមទារសំណងនៃការខូចខាតនោះទេ ដោយខ្លួនបានសុំដកពាក្យបណ្តឹងវិញ។ ដូច្នេះ ចំណុចនេះតុលាការគប្បីមិនលើកយកមកពិនិត្យពិចារណា និងសម្រេចនោះឡើយ។

៧. ចំពោះវត្ថុតាងដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៨១១ រ.វ.ត ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ គប្បីសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមវិញ ស្របតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរួមមាន៖
- ទូរស័ព្ទដៃចំនួន ១ គ្រឿង ម៉ាក Iphone ពណ៌ផ្កាឈូក (មិនដំណើរការ)។

៨. ដូចបានបញ្ជាក់ក្នុងសំអាងហេតុខាងលើនេះ តុលាការរកឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលកំណត់ និងប្រកាសបានថាឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា មានពិរុទ្ធភាពពីបទ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសឈ្មោះ [redacted] ពុធធារ៉ា ហៅ អាយ៉ា ភេទប្រុស អាយុ១៩ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ ពីបទ **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៨៤សេ ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២. ប្រគល់វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៨១១ រ.វ.ត ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ឱ្យទៅម្ចាស់ដើមវិញ ស្របតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមមាន៖
- ទូរស័ព្ទដៃចំនួន ១ គ្រឿង ម៉ាក Iphone ពណ៌ផ្កាឈូក (មិនដំណើរការ)។



Scanned with CamScanner

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងនៅក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|

ហត្ថលេខា និងត្រា៖ [redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner